**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០១ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ-រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីសន្តិសុខនាវា និងសន្តិសុខបរិវេណ-កំពង់ផែ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១:-**

ត្រូវបានបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ ដើម្បីធានាការងារអាជីវកម្ម ការថែរក្សាសន្តិសុខនាវាចរ សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថានល្អនៅក្នុងមណ្ឌលនេះ ។

## ជំពូកទី ២
## ការកំណត់ព្រំប្រទល់មណ្ឌលអាជីវកម្មផែភ្នំពេញ

**មាត្រា ២.–**

ព្រំប្រទល់មណ្ឌលអាជីវកម្មផែភ្នំពេញរួមមាន បីតំបន់ដូចខាងក្រោម ÷

**តំបន់ទី១ : ភ្នំពេញ ចតុមុខ ( ទន្លេសាប-មេគង្គ )**

១-ព្រំប្រទល់ផ្ទៃទឹក

ក- ខាងជើង

-ផ្នែកទន្លេសាប : ត្រើយខាងលិច ត្រឹមខ្សែស្របរយៈទទឹងខាងជើង ១២៨៣០០០ ជាប់ព្រំប្រទល់ខាងជើងរបស់ស្ថានីយស្តុកប្រេងឥន្ធនៈសូតឹម៉ិច ។ ត្រើយខាងកើត ចំភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

-ផ្នែកទន្លេមេគង្គ : ត្រើយខាងលិច ត្រឹមខ្សែស្របរយៈទទឹងខាងជើង ១២៨៤០០០ ចំភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ត្រើយខាងកើតចំភូមិព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្ត-កណ្តាល។

ខ- ខាងត្បូង

-ផ្នែកទន្លេបាសាក់ : ត្រឹមមាត់ទន្លេបាសាក់ ដែលបែកចេញពីចតុមុខ។

-ផ្នែកទន្លេមេគង្គ : ត្រឹមខ្សែរយៈបណ្តោយខាងកើត ៤៩៧០០០ ត្រង់ឃុំអរិយក្សត្រ និងឃុំវាលស្បូវ ។

២-ព្រំប្រទល់ផ្ទៃដីមាត់ទន្លេ

ក-ផ្នែកភ្នំពេញ : ត្រឹមចិញ្ចើមខាងកើតតិរិវិថីព្រះស៊ីសុវត្ថិ ទល់មាត់ទឹក ចាប់ពីរបងខាងជើងស្ថានីយស្តុកប្រេងឥន្ធនៈសូតឹម៉ិច ឫស្សីកែវ ត្រឹមខ្សែស្របរយៈទទឹងខាងជើង ១២៨៣០០០ មកខាងត្បូងរហូតដល់ព្រះគម្ពង់ ខាងមុខវត្តឧណ្ណាលោម ។

ខ-ផ្នែកជ្រោយចង្វារ : ចាប់ពីមាត់ច្រាំងរហូតដល់មាត់ទឹក ពីភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ខ្សែស្របរយៈទទឹងខាងជើង ១២៨៤០០០ រហូតដល់ភូមិកណ្តាល ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ខ្សែរយៈបណ្តោយខាងកើត ៤៩៧០០០ ។

**តំបន់ទី២ : ទន្លេមេគង្គលើ ( ចតុមុខ-ទន្លេបិទ )**

ចាប់ពីចំណុចចុងកោះឧញ៉ាតី ខ្សែស្របរយៈទទឹងខាងជើង ១២៨៤០០០ (PK 353+800) រហូតដល់ទន្លេបិទ ខ្សែស្របរយៈទទឹងខាងជើង ១៣២៤៦០០ (PK 447) ។

**តំបន់ទី៣: ទន្លេមេគង្គក្រោម ( ចតុមុខ-អ្នកលឿង )**

ចាប់ពីភូមិវាលស្បូវ ខ្សែរយៈបណ្តោយខាងកើត ៤៩៧០០០ (PK 344+600) រហូតដល់អ្នកលឿង ខ្សែស្របរយៈទទឹងខាងជើង ១២៤៣៣០០ (PK 292) ។

ផែនទីកំណត់ព្រំប្រទល់ការគ្រប់គ្រងមណ្ឌលអាជីវកម្មផែភ្នំពេញ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រងមណ្ឌលអាជីវកម្មផែភ្នំពេញ

**មាត្រា ៣ៈ_**

មណ្ឌលអាជីវកម្មផែភ្នំពេញ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់កំពង់ផែស្វយ័តភ្នំពេញ។

**មាត្រា ៤ៈ_**

ហេដ្ឋារចនាសម្ព័ន្ធផែ ដែលមាននៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់កំពង់ផែស្វយ័តភ្នំពេញ។

ដោយឡែក ទ្រព្យសម្បត្តិរបស់រដ្ឋដទៃទៀត ដែលស្ថិតនៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ជាសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន រាជធានី និងខេត្តសាមី។

**មាត្រា ៥ៈ_**

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផែ ក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ត្រូវមានការឯកភាពពីកំពង់ផែស្វយ័តភ្នំពេញ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៦ៈ_**

ការងារអាជីវកម្ម និងការគ្រប់គ្រងមណ្ឌលអាជីវកម្មផ្សេងៗកន្លងមក ដែលស្ថិតនៅក្នុងក្របខណ្ឌ នៃអនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៦ ត្រូវបន្តសុពលភាពស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៧ៈ_**

អនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៦ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ ៤

**មាត្រា ៨:—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន អភិបាលរាជធានីភ្នំពេញ និងខេត្តពាក់ព័ន្ធ ព្រមទាំងកំពង់ផែស្វយ័តភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

ឧបសម្ព័ន្ធ
អនុក្រឹត្យលេខ ០១ អនក្រ.បក
ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩
ស្តីពីការបង្កើតមណ្ឌលអាជីវកម្មដីភ្នំពេញ




| ភ្នំពេញ - ក្អមសំណរ | |
|---|---|
| 1- ចតុមុខ | L=10,000m ,D=-15m |
| 3- ព្រែកឯងកើត | L=1,280m , D=-15m |
| 5- កោះក្របី | L=12,000m ,D=-10m |
| 7- កោះកែវ | L=4,600m , D=-15m |
| 9- ព្រែកជ្រៃ | L=3,100m , D=-15m |
| 11- ពាមរាំង | L=3,600m , D=-15m |

| ភ្នំពេញ - កំពង់ចាម | |
|---|---|
| 2- កោះដាច់ | L=11,000m ,D=-10m |
| 4- តាឯក | L=11,000m ,D=-10m |
| 6- ស្ពឺ | L=8,000m , D=-5m |
| 8- ព្រែកតាកូវ | L=3,100m , D=-5m |
| 10- កំពង់ចាម | L=15,000m , D=-5m |

បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី ៣០ ខែ ១២ ឆ្នាំ ២០០៨
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក...
ហ៊ី_ឫទ្ធី